**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៩៤០ **អយក.**ហវ

ថ្ងៃច័ន្ទ ២កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ជម្រាបមក**

- **ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
- **ឯកឧត្តម លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្ដីការក្រសួង**

**កម្មវត្ថុ ៖** ករណីបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីពេញលេញរបស់អង្គភាពនៅរដ្ឋបាលកណ្ដាលក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២១។

**យោង ៖** -ប្រកាសលេខ៦៦៣ សហវ.ហក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-លិខិតលេខ៤២៤៧ អយក.ហវ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ជ្រាបថា៖ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ក្រសួងបានអញ្ជើញមន្ត្រីជំនាញនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមប្រជុំណែនាំនិងផ្សព្វផ្សាយនៃប្រកាសលេខ៦៦៣ សហវ.ហក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិជូនអង្គភាពក្រោមឱវាទក្រសួងក្នុងគោលបំណងចូលរួមចំណែកលើកកម្ពស់សមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យយល់កាន់តែច្បាស់លាស់អំពីយន្តការនៃការគ្រប់គ្រងហិរញ្ញវត្ថុតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន រីឯការអនុវត្តថវិកាចាប់ពីឆ្នាំ២០២១ តទៅត្រូវអនុលោមតាមប្រកាសថ្មីនេះ។ ក្នុងន័យនេះ ដើម្បីពង្រឹងការទទួលខុសត្រូវលើការប្រើប្រាស់ថវិកាឱ្យទាន់ពេលវេលានិងមានប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំកំណត់សម្រាប់ការបង្កើតរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២១ ដូចខាងក្រោម ៖

១-ត្រូវបញ្ជូនតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីចុងក្រោយបង្អស់ក្នុងឆ្នាំ២០២០ មកនាយកដ្ឋានហិរញ្ញវត្ថុ (ការិយាល័យជំនាញ) ឱ្យបានមុន**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០**។

២-ការបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ដោយត្រូវជ្រើសរើសយកតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃគណនីនិងអនុគណនីក្នុងជំពូក៦០(ការទិញ) ជំពូក៦១(សេវាកម្ម) និងជំពូក៦៥(ឧបត្ថម្ភធន) តែប៉ុណ្ណោះ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ៖ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

៣-ទំហំឥណទានថវិកាដែលត្រូវបានជ្រើសរើសពីអនុគណនីនីមួយៗសម្រាប់រៀបចំបង្កើតរដ្ឋទេយ្យបុរេប្រទាន ត្រូវអនុលោមទៅតាមមុខសញ្ញាចំណាយលម្អិត ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ជាកំហិត។

៤-អង្គភាពថវិកា ត្រូវរៀបចំបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទាំងពីរប្រភេទតាមចំណាត់ថ្នាក់សេដ្ឋកិច្ច(ជំពូក គណនី អនុគណនី) និងចំណាត់ថ្នាក់កម្មវិធី(កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) ព្រមទាំងលិខិតស្នើសុំ ឱ្យបានយ៉ាងយូរត្រឹមបំណាច់**សប្តាហ៍ទី៣នៃខែវិច្ឆិកា ឆ្នាំ២០២០** ដើម្បីបានពិគ្រោះយោបល់ជាមុនជាមួយនឹងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងនិង/ឬគណនេយ្យករសាធារណៈនៅអគ្គនាយកដ្ឋានរតនាគារជាតិ។

៥-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងក្នុងករណីមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំបង្កើតរដ្ឋទេយ្យបុរេប្រទាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់និងទាន់ពេលវេលា តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- គ្រប់អគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ .នា. ហិរញ្ញវត្ថុ